# សុន្ទរកថា

## ឯកឧត្តមវេជ្ជបណ្ឌិត ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ថ្លែងក្នុងពិធីបើកការប្រជុំភាគីពាក់ព័ន្ធ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ

សណ្ឋាគារ Naga World រាជធានីភ្នំពេញ **ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣**

-សូមគោរព លោកវេជ្ជ. CHRISTOPHEL Eva Maria តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា

-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងស្ថាប័នពាក់ព័ន្ធ តំណាងអង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយទាំងអស់ ព្រមទាំងសមាជិក សមាជិកា នៃអង្គប្រជុំទាំងមូលជាទីមេត្រី!

ក្នុងនាមក្រសួងសុខាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ថ្ងៃនេះខ្ញុំមានមនោសញ្ចេតនារីករាយ និងមានកិត្តិយសដែលបានចូលរួមក្នុងពិធីបើកការប្រជុំភាគីពាក់ព័ន្ធ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ក្រោយពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ បានបំពេញបេសកកម្មអស់រយៈកាលច្រើនទសវត្សរ៍មក ក្រសួងសុខាភិបាលបានពិនិត្យឡើងវិញ និងអនុម័តលើឯកសារស្តីពីរចនាសម្ព័ន្ធ និងដំណើរការរបស់មជ្ឈមណ្ឌលនេះនៅចុងឆ្នាំ២០១២ ដោយអនុលោមតាមសភាពការណ៍បច្ចុប្បន្ន ក្នុងនោះមានការតម្រូវតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល និងតាមនិន្នាការនៃភាគីពាក់ព័ន្ធទាំងក្នុងប្រទេស និងក្នុងឆាកអន្តរជាតិ ។

បេសកកម្មរបស់មជ្ឈមណ្ឌលនេះគឺអន្តរាគមន៍ឆ្លើយតបនឹងជំងឺគ្រុនចាញ់ គ្រុនឈាម ជំងឺប៉ារ៉ាស៊ីត និងជំងឺបង្កដោយវីរុសមួយចំនួនទៀត ដែលចំលងដោយមូស ។ រាជរដ្ឋាភិបាលជានិច្ចកាលបានឧបត្ថម្ភ គាំទ្រដល់សកម្មភាពប្រយុទ្ធ ឬលុបបំបាត់ជំងឺទាំងនេះ តាមរយៈកម្មវិធីជាតិចំនួនពាគឺ: ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និង ជំងឺដង្កូវព្រូន ក្នុងនោះ ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើមដោយផ្ទាល់ឱ្យក្រសួងសុខាភិបាលរៀបចំ និងដាក់ឱ្យដំណើរការផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ ២០១១-២០២៥ ។

ក្នុងរយៈពេល៥ឆ្នាំ ២០០៨-២០១៣ យើងបានចែកមុងជ្រលក់ថ្នាំប្រសិទ្ធភាពយូរចំនួនជាង ៦លានមុងក្នុងនោះមុង ៣លាន៧សែន ចែកក្នុងឆ្នាំ ២០១១-២០១២ ដែលជាដំណាក់កាល២ឆ្នាំដំបូងនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០១១-២០២៥។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ក្នុងរយៈពេលចុងក្រោយនេះ អត្រាស្លាប់ដោយជំងឺគ្រុនចាញ់បានថយចុះជាបន្តបន្ទាប់ ក្នុងនោះយើងសង្កេតឃើញថា ឆ្នាំ២០១០ ស្លាប់ **១៥១**នាក់ ឆ្នាំ២០១១ ចុះមកដល់ ***៩៣***នាក់ ឆ្នាំ២០១២ ចុះមកត្រឹម៤៥ គឺត្រូវបានកាត់បន្ថយ **៣៨**% ក្នុងឆ្នាំ២០១១ និង **៥២**%ក្នុងឆ្នាំ២០១២។ ជាពិសេសក្នុង ១០ខែដើមឆ្នាំ២០១៣ នេះ ចំនួនស្លាប់ដោយគ្រុនចាញ់មាន ៨នាក់ គឺថយចុះ **៧៨%** បើប្រៀបធៀបរយៈពេលដូចគ្នា ឆ្នាំ២០១២ ដែលមានរហូតដល់ **៣៧**នាក់ ដែលជាការកាត់បន្ថយក្នុងល្បឿនលឿន ព្រោះក្នុងទសវត្សឆ្នាំ២០០០-២០១១ ករណីស្លាប់ដោយគ្រុនចាញ់ថយចុះជាមធ្យមប្រហែល **៧,៧**% ប៉ុណ្ណោះក្នុង១ឆ្នាំៗ។ អត្រាស្លាប់គ្រុនចាញ់ក្នុងប្រជាជន ១សែននាក់ដែលជា ***សូចនាករស្នូល១*** នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាបានថយចុះពី ៥,២៩ នាក់ នាឆ្នាំ២០០០ មកនៅត្រឹម ០,៦៧ នាក់ នាឆ្នាំ ២០១១ និង ០,៣២នាក់ នាឆ្នាំ២០១២ ក្នុងខណៈដែលកម្ពុជាបានកំណត់គោលដៅរបស់ខ្លួនរហូតដល់ ០,៧៨នាក់ សំរាប់ឆ្នាំ២០១៥ ពោលគឺយើងសំរេចគោលដៅបាន៣ឆ្នាំមុនកាលកំណត់។ ចំនួនករណីគ្រុនចាញ់ព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ឬមណ្ឌលសុខភាពរដ្ឋ ឬដោយភ្នាក់ងារស្ម័គ្រចិត្តឆ្នាំ២០១២ មាន ៦៩,៥១៥នាក់គឺថយចុះ៣៥% បើប្រៀបធៀបឆ្នាំ២០១១ដែលមាន១០៦,៧៧៦នាក់។ ក្នុង១០ខែដើមឆ្នាំ២០១៣ ចំនួនករណីគ្រុនចាញ់ដែលព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ឬមណ្ឌលសុខភាពរដ្ឋ ឬភ្នាក់ងារស្ម័គ្រចិត្តភូមិមាន ***៣៣,៧៦៩*** ករណី គឺថយចុះ **៤៣%** បើប្រៀបធៀបរយៈពេលដូចគ្នាឆ្នាំ២០១២ ដែលមាន ***៥៩,៦៦៨*** ករណី ដូច្នេះជំងឺគ្រុនចាញ់លែងជាមូលហេតុចំបងនៃការស្លាប់ទូទៅរបស់ប្រជាជនកម្ពុជាទៀតហើយ។ ប៉ុន្តែទោះបីយ៉ាងដូច្នេះក្តីក៏យើងមិនបន្ធូរបន្ថយក្នុងការប្រយុទ្ធនឹងជំងឺនេះដែរព្រោះ អត្រាឈឺ និងស្លាប់នឹងអាចកើនឡើងវិញភ្លាម បើប្រសិនមេរោគគ្រុនចាញ់នៅតែបន្តបណ្តែតខ្លួនក្នុងឈាមមនុស្ស គឺមូសដែកគោលញី នៅតែមានឱកាសខាំចំលងមេរោគនេះពីមនុស្សម្នាក់ទៅម្នាក់ទៀតបានដដែល។ យើងនៅមានការងារជាច្រើនទៀតត្រូវធ្វើដើម្បីធ្វើយ៉ាងណាលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យអស់ទាំងស្រុងនៅឆ្នាំ២០២៥ ដោយមូលហេតុថាៈ

-ចលនាប្រជាជនចល័តទៅធ្វើការនៅតំបន់គ្រុនចាញ់ក្នុងប្រទេស និងក្រៅប្រទេសជាកង្វល់ ដែលទាមទារការពិភាក្សាស្វែងរកអន្តរាគមន៍ជាក់ស្តែង មានប្រសិទ្ធភាពក្នុងការដោះស្រាយដោយសហការជាមួយវិស័យឯកជន ដូចជាម្ចាស់ការដ្ឋានកសិកម្ម -រ៉ែ គមនាគមន៍ និងប្រទេសជិតខាងយើង។

-ពូជធាតុខ្សែស្រឡាយមេរោគគ្រុនចាញ់ប្រភេទផ្លាស្មូឌីយ៉ូមនៅកម្ពុជា មានលក្ខណៈពិសេសអាចសម្រប ខ្លួនស៊ាំទៅនឹងឱសថព្យាបាលគ្រុនចាញ់គ្រប់ប្រភេទ ជាបន្តបន្ទាប់ ជាងកន្លះសតវត្សមកហើយ ក្នុងនោះរួមមានភាពស៊ាំនឹងឱសថក្លរ៉ូគីន ហ្វង់ស៊ីដា ហើយថ្មីៗនេះ ជាមួយអាតេមីស៊ីនីន ផង។ ដោយឡែកភាពស៊ាំនឹងអារតេមីស៊ីនីន មិនមែនមានតែនៅកម្ពុជាទេ គឺជាបញ្ហាតាមសងខាងបណ្តោយព្រំដែននៃប្រទេសក្នុងអនុតំបន់មេគង្គ ហេតុនេះ សូមអង្គប្រជុំពិភាក្សាផ្តល់អនុសាសន៍ឆ្លើយតបឱ្យទាន់សភាពការណ៍ជាក់ស្តែង។

-ចំពោះជំងឺគ្រុនឈាមវិញ កម្ពុជាជាប្រទេសមួយដែលមានគ្រុនឈាមច្រើនទសវត្សរ៍មកហើយ ទោះបីប្រទេសមានសេដ្ឋកិច្ចជឿនលឿនក៏ពុំទាន់អាចជៀសផុតពីការផ្ទុះរាតត្បាតនៃជំងឺនេះដែរ។ យើងត្រូវមានការប្រុងប្រយ័ត្នជានិច្ច ទោះបីឆ្នាំ ២០១៣នេះកម្ពុជាពុំត្រូវចំឆ្នាំ ដែលត្រូវផ្ទុះជំងឺគ្រុនឈាមតាមការកត់សំគាល់របស់អង្គការសុខភាពពិភពលោកដែលថា ក្នុងប្រទេសនីមួយៗមានផ្ទុះជំងឺគ្រុនឈាមក្នុង៣-៥ឆ្នាំ ម្តងក្តី។

-ចំណែកឯជំងឺដង្កូវព្រូន សូមធ្វើសកម្មភាពដោយផ្តល់អាទិភាពដល់ការរក្សាអត្រាគ្របដណ្តប់ការផ្តល់ថ្នាំទំលាក់ព្រូននៅតាមសាលារៀនឱ្យនៅខ្ពស់ជាង៩០% ហើយសូមពង្រីកអត្រាគ្របដណ្តប់សំរាប់ស្ត្រីក្នុងវ័យបន្តពូជដើម្បីរួមចំណែកលើកកំពស់សុខភាពមាតា និងកុមារ។

-ខ្ញុំសូមឱ្យមជ្ឈមណ្ឌលរៀបចំឱ្យចប់នូវផែនការប្រតិបត្តិឆ្នាំ២០១៤ ឱ្យរួចរាល់មុនដំណាច់ខែធ្នូ។ អង្គភាពសុខាភិបាលគ្រប់ថ្នាក់ ត្រូវមានផែនការប្រចាំឆ្នាំ និងផែនការរំកិល៣ឆ្នាំ។ ទន្ទឹមនឹងនេះ ខ្ញុំសូមអំពាវនាវដល់ភាគីពាក់ព័ន្ធជាពិសេស ភាគីម្ចាស់ជំនួយសូមមេត្តាសហការផ្តល់ព័ត៌មានសមស្រប ដើម្បីអង្គភាពសុខាភិបាលនីមួយៗមានលទ្ធភាពរៀបចំផែនការឱ្យបានត្រឹមត្រូវដោយតម្លាភាព។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះបណ្តាប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ព្រមទាំងស្ថានប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដែលបានខិតខំប្រឹងប្រែងផ្តល់ការគាំទ្រ ទាំងស្មារតី សំភារៈ និងថវិកាដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណេកសាស្ត្រ បំពេញបេសកម្មរហូតទទួលបានលទ្ធផលល្អប្រសើរកន្លងមក។ ខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំផង

ដែរថា ម្ចាស់ជំនួយ និងដៃគូទាំងអស់នឹងនៅតែបន្តជួយដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និងធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធថែមទៀត ដើម្បីចូលរួមកាត់បន្ថយអត្រាឈឺ/ស្លាប់ដោយសារជំងឺគ្រុនចាញ់ គ្រុនឈាម ដង្កូវព្រូន និងជំងឺផ្សេងៗទៀតដែលចំលងដោយមូស ។

ជាទីបញ្ចប់ ក្នុងនាមក្រសួងសុខាភិបាល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមជូនពរបវរមហាប្រសើរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិក សមាជិកានៃអង្គពិធីទាំងមូល សូមប្រកបដោយពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើកការប្រជុំភាគីពាក់ព័ន្ធ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រនិង បាណកសាស្ត្រ ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**